

# កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ៖ ប័ណ្ណសមធម៌តាមការស្នើសុំសម្រាប់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ

ចេញផ្សាយ ខែធ្នូ ឆ្នាំ២០២២

អង្គការសមាគមធាងត្នោត
Sahmakum Teang Tnaut Organization · a Cambodian Urban NGO

# មាតិកា


១. សេចក្តីផ្តើម.....១
១.១. តើកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រគឺជាអ្វី?.....១
១.២. អត្ថប្រយោជន៍នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ.....២
១.៣. ដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ.....២
២. វិធីសាស្រ្តស្រាវជ្រាវ.....៤
២.១. គោលបំណង.....៤
២.២. លក្ខខណ្ឌជ្រើសរើស និងទំហំ.....៤
២.៣. ការប្រមូលព័ត៌មាន.....៤
២.៤. ដែនកំណត់.....៤
៣. ការរកឃើញសំខាន់ៗ.....៦
ផ្នែកទី ១៖ ព័ត៌មានទូទៅអំពីការទទួលបានប័ណ្ណសមធម៌.....៦
ផ្នែកទី ២៖ ព័ត៌មានទូទៅអំពីសហគមន៍ដែលមិនមានប័ណ្ណសមធម៌.....៨
ផ្នែកទី ៣៖ ដំណើរការនៃការចែកប័ណ្ណសមធម៌របស់អាជ្ញាធរមូលដ្ឋាន.....៨
ផ្នែកទី ៤៖ នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ.....៩
៤. សេចក្តីសន្និដ្ឋាន.....១១
៥. អនុសាសន៍.....១២

# ១. សេចក្តីផ្តើម

## ១.១ តើកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រគឺជាអ្វី?

កម្មវិធី "អត្តសញ្ញាណកម្មគ្រួសារក្រីក្រ" ជាយន្តការគាំពារសង្គមមួយដំបូងបង្អស់របស់ប្រទេសកម្ពុជា ដែលបង្កើតឡើងជាមូលដ្ឋានតែមួយគត់សម្រាប់កម្មវិធីនានាដែលផ្តោតទៅលើប្រជាពលរដ្ឋក្រីក្រ។ កម្មវិធីនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដោយក្រសួងផែនការ ក្នុងគោលបំណងចូលរួមកាត់បន្ថយភាពក្រីក្រ និងគាំទ្រដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៅទូទាំងប្រទេសកម្ពុជា។[១]

៥០ ភាគរយ នៃចំនួនប្រជាពលរដ្ឋកម្ពុជាសរុប ត្រូវបានប៉ាន់ប្រមាណថា មានជីវភាពក្រីក្រ ឬងាយធ្លាក់ក្នុងភាពក្រីក្រ។[២] ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ មិនទាន់មាននីតិវិធីណាមួយដែលមានលក្ខណៈស្តង់ដារដែលអាចវាស់វែងពីភាពក្រីក្រនៅឡើយទេ មុនពេលមានកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា។ ថ្វីត្បិតតែមានកម្មវិធីផ្តល់ការការពារសង្គមសម្រាប់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រជាច្រើនក្តី កម្មវិធីនីមួយៗ និងស្ថាប័នអនុវត្តកម្មវិធីទាំងនោះមានលក្ខណៈវិនិច្ឆ័យ និងនីតិវិធីដំណើរការរបស់ខ្លួនផ្សេងៗគ្នា ក្នុងការកំណត់គ្រួសារក្រីក្រ ដែលជាទូទៅមិនមានប្រសិទ្ធផលជំនួយមិនទៅដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ ហើយគ្រួសារក្រីក្រទាំងនោះ មិនអាចអនុវត្តសិទ្ធិរបស់ពួកគេក្នុងការទទួលបានសេវាមូលដ្ឋានសង្គម ដូចជាការព្យាបាល និងការអប់រំដោយឥតគិតថ្លៃឡើយ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងផែនការបានរៀបចំប្រព័ន្ធកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្មីមួយ ដោយមានការគាំទ្រពីធនាគារពិភពលោក កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ និងជាពិសេសពីរាជរដ្ឋាភិបាលអាល្លឺម៉ង់ តាមរយៈទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសអាល្លឺម៉ង់ (GIZ)។[៣] ដំណើរការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវបានកែលម្អថ្មីៗនេះ នៅក្នុងឆ្នាំ ២០២០ ក្រោមការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសអាល្លឺម៉ង់ (GIZ) និងក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT)។

បច្ចុប្បន្នប្រព័ន្ធកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានលក្ខណៈបែបឌីជីថលទាំងស្រុង ក្រោយពីមានការវិវឌ្ឍ និងការកែលម្អឱ្យប្រសើរជាងមុន ក្នុងពេលសាកល្បងដំណាក់កាលដំបូងក្នុងឆ្នាំ ២០០៧។ រាល់ការប្រមូលទិន្នន័យ ត្រួតពិនិត្យ និងផ្សព្វផ្សាយព័ត៌មានឥឡូវនេះ អាចធ្វើបានតាមរយៈប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រឌីជីថល ក្នុងនោះរួមមានគេហទំព័រ និងកម្មវិធីទូរស័ព្ទដែលផ្តល់ភាពងាយស្រួលដល់សហគមន៍ក្រីក្រនៅតាមទីប្រជុំជន និងជនបទក្នុងការទទួលបានសេវាសង្គមសំខាន់ៗ។ មុនពេលមានការបំលែងទៅជាប្រព័ន្ធឌីជីថលនេះ នីតិវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវបានធ្វើឡើងតាមរយៈការជួបសម្ភាសផ្ទាល់។ អាជ្ញាធរត្រូវទៅជួបសម្ភាសជាមួយសហគមន៍ ដើម្បីវាយតម្លៃស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ពួកគេ។

នៅក្នុងឆ្នាំ ២០០៧ គម្រោងសាកល្បងត្រូវបានអនុវត្ត នៅទីជនបទចំនួន៤ឃុំ។ បន្ទាប់មក នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ ត្រូវបានអនុវត្តនៅតាមខេត្តចំនួន ៨ខេត្ត ក្នុងមួយឆ្នាំៗ និងគ្របដណ្តប់ទូទាំង ២៤ខេត្តក្រុងនៃប្រទេសកម្ពុជាក្នុងរយៈពេលបីឆ្នាំ គិតត្រឹមឆ្នាំ ២០១១។ ដំបូងឡើយ កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតាមទីជនបទតែប៉ុណ្ណោះ ក៏ប៉ុន្តែនៅក្នុងឆ្នាំ២០១៦ កម្មវិធីនេះ ត្រូវបានពង្រីកទៅដល់តំបន់ទីប្រជុំជនបន្ថែមទៀត។[៤] សព្វថ្ងៃ ប្រជាពលរដ្ឋរាប់ពាន់នាក់នៅទូទាំងប្រទេសកម្ពុជាបានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធនេះ។

---

[១] Kaba Mary White, Baesel Klaus, Poch Bunnak, Bun Samnang, Cerceau Sabine, Bury Louise et al. អត្តសញ្ញាណកម្មគ្រួសារក្រីក្រ៖ កម្មវិធីកំណត់ភាពក្រីក្រដែលអាចឱ្យមានការសហការពីគ្រប់វិស័យសម្រាប់សុខភាពមាតានិងកុមារនៅកម្ពុជា BMJ ឆ្នាំ២០១៨

[២] អង្គការ UNDP និង OPHI ឆ្នាំ២០២១ សន្ទស្សន៍សកលនៃភាពក្រីក្រពហុសមាសភាព (MPI)៖ លាតត្រដាងពីភាពខុសគ្នារវាងជាតិសាសន៍ វណ្ណៈ និងយេនឌ័រ ឆ្នាំ២០២១ ទំព័រទី ៣២

[៣] GIZ ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ គេហទំព័រ https://www.giz.de/en/worldwide/17300.htm

ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានរៀបចំ និងបង្កើតឡើងផ្អែកលើច្បាប់សំខាន់ៗក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តអនុក្រឹត្យលេខ ២៩១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងខែធ្នូ ឆ្នាំ ២០១១។[៦] អនុក្រឹត្យនេះកំណត់ពីការគ្រប់គ្រង និងអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រនៅក្នុងប្រទេសកម្ពុជា។ អនុក្រឹត្យលេខ ២៩១ តម្រូវឱ្យ "ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានទាំងអស់ដែលមានបំណងផ្តល់សេវា ឬជំនួយដល់គ្រួសារ ឬជនក្រីក្រ រួមទាំងការអន្តរាគមន៍បន្ទាន់ទាំងឡាយណាដែលសមស្រប ត្រូវប្រើប្រាស់ជាចម្បងនូវទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិដែលមានសុពលភាព។"[៧]

## ១.២. អត្ថប្រយោជន៍នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រមានគោលដៅផ្តល់សេវា និងជំនួយអភិវឌ្ឍន៍ឱ្យចំគ្រួសារក្រីក្រដែលងាយរងគ្រោះ ដើម្បីជួយឱ្យគ្រួសារទាំងនោះរួចផុតពីភាពក្រីក្រ និងការពារពួកគេពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុនានា។[៨] កម្មវិធីនេះប្រមូលទិន្នន័យពីគ្រួសារក្រីក្រ និងភ្ជាប់គ្រួសារក្រីក្រទាំងនោះទៅអង្គភាព និងស្ថាប័នពាក់ព័ន្ធដែលអាចផ្តល់ជំនួយជាក់លាក់ដែលពួកគេត្រូវការជាចាំបាច់។ អត្ថប្រយោជន៍នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររួមមាន៖

- ការផ្តល់សេវាថែទាំ និងព្យាបាលដោយឥតគិតថ្លៃ ឬបញ្ចុះតម្លៃ និងការទទួលបានការទូទាត់ជាសាច់ប្រាក់មកវិញនូវថ្លៃសេវាពាក់ព័ន្ធ (ដូចជាតាមរយៈមូលនិធិសមធម៌សុខាភិបាល ឬការធានារ៉ាប់រងសុខភាពសង្គម)។[៩]
- អាហារូបករណ៍ ការលើកលែងបង់ថ្លៃសេវាអប់រំ ឬការគាំទ្រផ្នែកហិរញ្ញវត្ថុផ្សេងៗដល់កុមារក្រីក្រសម្រាប់ការអប់រំចំណេះដឹងទូទៅ និងវគ្គបណ្តុះបណ្តាលការងារ។
- សេវាពាក់ព័ន្ធវិស័យកសិកម្ម ដូចជាការចែកជូនសម្ភារៈកសិកម្ម (ជី គ្រាប់ពូជ និងសត្វចិញ្ចឹម) និងវគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើកសិកម្ម និងចិញ្ចឹមសត្វ។
- ការបែងចែកដីសម្បទានសង្គមកិច្ច។
- ការចែកជូនចំណីអាហារឥតគិតថ្លៃ (អាហារបំប៉ន និងអាហារចាំបាច់បន្ទាន់) និងតម្រូវការមូលដ្ឋាន។
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ (ដើម្បីធ្វើឱ្យប្រសើរឡើងអំឡុងវិបត្តិនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ជំនួយសង្គ្រោះបន្ទាន់ត្រូវបានផ្តល់ជូនជាអាហាររូបត្ថម្ភសម្រាប់មាតា និងកុមារ ការអប់រំ និងការថែទាំសុខភាពនានា)។
- ថ្លៃតភ្ជាប់ប្រព័ន្ធទឹកស្អាត ដូចជាការបញ្ចុះតម្លៃសម្រាប់ការប្រើប្រាស់ទឹកស្អាត។

## ១.៣. ដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ចាប់តាំងពីការសាកល្បងគម្រោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅឆ្នាំ ២០០៧ មក ដំណើរការអត្តសញ្ញាណកម្មមានការអភិវឌ្ឍ និងត្រូវបានបំប្លែងទៅជាប្រព័ន្ធឌីជីថលនៅក្នុងឆ្នាំ ២០២០។ មុនឆ្នាំ ២០២០ ភាពជោគជ័យនៃនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវពឹងផ្អែកលើសមត្ថភាព និងភាពប្រឹងប្រែងរបស់អាជ្ញាធរ ដែលត្រូវចុះជួបផ្ទាល់ជាមួយសហគមន៍ជារៀងរាល់បីឆ្នាំម្តង ដើម្បីសម្ភាស និងបញ្ចូលទិន្នន័យគ្រួសារទៅក្នុងប្រព័ន្ធទិន្នន័យគ្រួសារក្រីក្រ ដោយប្រើប្រាស់កម្រងសំណួរស្តង់ដារ។[១០] ស្ថានភាពក្រីក្ររបស់សហគមន៍ត្រូវបានចងក្រង ដោយយោងលើព័ត៌មានទាក់ទងនឹងទ្រព្យសម្បត្តិ សុខភាព ការអប់រំ ប្រាក់ចំណូល និងបំណុល។ បន្ទាប់មក ប័ណ្ណសមធម៌ត្រូវបានចែកទៅគ្រួសារក្រីក្រដែលអាចទទួលបានសេវាដូចជាទឹកស្អាត ការអប់រំ សម្ភារៈកសិកម្ម សេវាថែទាំសុខភាព និងការឧបត្ថម្ភសាច់ប្រាក់ជាដើម។

នៅក្នុងឆ្នាំ ២០២២ សេវាដែលផ្តល់ដោយប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅមានដដែរ។ យ៉ាងណាមិញ ដំណើរការ

[៤] ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ មិនទុកចោលនរណាម្នាក់៖ ការយល់ដឹងពីប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាតិនៅកម្ពុជា ឆ្នាំ២០១៧ ទំព័រទី ៥
[៥] ក្រសួងផែនការនៃកម្ពុជា ដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គេហទំព័រ https://mop.idpoor.gov.kh/about/process
[៦] ដូចខាងលើ
[៧] អនុក្រឹត្យលេខ ២៩១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឆ្នាំ២០១១ ជំពូកទី ៤ មាត្រា ១៧
[៨] ក្រសួងផែនការនៃកម្ពុជា កម្មវិធីស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាតិ ជាឧបករណ៍សំខាន់មួយសម្រាប់គាំទ្រដល់ការអភិវឌ្ឍប្រកបដោយសមភាព ឆ្នាំ ២០០៩ ទំព័រទី ២
[៩] ដូចខាងលើ ទំព័រទី ២
[១០] ដូចខាងលើ

តាមប្រព័ន្ធឌីជីថលអនុញ្ញាតឱ្យនីតិវិធីអត្តសញ្ញាណកម្មមានភាពងាយស្រួល និងអាចឱ្យអ្នកទទួលផលពីកម្មវិធីនេះធ្វើបច្ចុប្បន្នភាព ហើយអាចកែប្រែព័ត៌មានរបស់ពួកគេនៅក្នុងប្រព័ន្ធបានគ្រប់ពេលវេលា។ ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ អាចប្រើប្រាស់ជាប្រព័ន្ធអនឡាញបាន ដូចនេះគ្រួសារក្រីក្រទាំងនោះអាចស្នើសុំបញ្ចូលពួកគេ ទៅក្នុងបញ្ជីជារៀងរាល់ខែ ដោយគ្រាន់តែស្នើសុំការសម្ភាសតាមរយៈប្រធានភូមិ ឬក្រុមប្រឹក្សាឃុំ។[១១]

ដំណើរការទាំងមូលគឺស្ថិតក្រោមការត្រួតពិនិត្យ គ្រប់គ្រង និងសម្របសម្រួលដោយក្រសួងផែនការ។ ក្រសួងផែនការទទួលខុសត្រូវលើដំណើរការនៅថ្នាក់ជាតិ។ បន្ថែមពីនេះ ក្រសួងផែនការដើរតួនាទីជាអ្នកតភ្ជាប់រវាងទិន្នន័យដែលត្រូវបានបញ្ចូលក្នុងប្រព័ន្ធ ជាមួយនឹងក្រសួង និងស្ថាប័នពាក់ព័ន្ធដូចជាក្រុមប្រឹក្សាជាតិសន្តិសុខសង្គម។

នៅក្នុងខេត្តនីមួយៗ ត្រូវបានគេរំពឹងថាមានគណៈកម្មាធិការរបស់ខ្លួន ដែលមានលេខាធិការទទួលខុសត្រូវលើដំណើរការ និងនីតិវិធីប្រចាំថ្ងៃនៅថ្នាក់ក្រោមជាតិ ដូចជាត្រួតពិនិត្យការប្រមូលទិន្នន័យ និងចែកប័ណ្ណសមធម៌។ ឃុំ ឬសង្កាត់មានក្រុមការងារពីរក្នុងមូលដ្ឋានគឺជាក្រុមការងារឃុំ ឬសង្កាត់នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រងាយរងគ្រោះ និងក្រុមការងារថ្នាក់ភូមិ។ ក្រុមការងារថ្នាក់ភូមិដែលរួមមានប្រធានភូមិ និងអនុប្រធានភូមិ ធ្វើការចងក្រង និងធ្វើបច្ចុប្បន្នភាពបញ្ជីគ្រួសារក្រីក្រ ជាប្រចាំនៅក្នុងសហគមន៍។

បន្ទាប់មក ក្រុមការងារឃុំ ឬសង្កាត់ ប្រើប្រាស់ព័ត៌មានដែលបានពីក្រុមការងារថ្នាក់ភូមិ ដើម្បីចាត់ចែងសំណើសុំសម្ភាស និងធ្វើការសម្ភាស ដើម្បីផ្តល់ប័ណ្ណសមធម៌ដល់គ្រួសារក្រីក្រ។ ក្រោយពីសហគមន៍ទទួលបានប័ណ្ណសមធម៌ គ្រួសារក្រីក្រអាចត្រូវបានធ្វើបច្ចុប្បន្នភាពព័ត៌មានណាមួយទាក់ទងនឹងស្ថានភាពរបស់ពួកគេដែលអាចឈានដល់ការដកយកប័ណ្ណសមធម៌នោះវិញ ឧទាហរណ៍ដូចជាក្នុងករណីស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេមានភាពល្អប្រសើរ។ ប្រព័ន្ធឌីជីថលនេះក៏អនុញ្ញាតឱ្យសមាជិកលើកការតវ៉ាជំទាស់ និងផ្តល់យោបល់ណែនាំទាក់ទងនឹងនីតិវិធីប្រព័ន្ធទាំងមូលបានយ៉ាងងាយស្រួលផងដែរ។

[១១] ក្រសួងផែនការនៃកម្ពុជា កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាតិ៖ ឧបករណ៍សំខាន់សម្រាប់គាំទ្រការអភិវឌ្ឍប្រកបដោយសមភាព ឆ្នាំ ២០០៩

# ២. វិធីសាស្ត្រស្រាវជ្រាវ

### ២.១. គោលបំណង

របាយការណ៍នេះ ត្រូវបានរៀបចំឡើង ដើម្បីវាយតម្លៃអំពីភាពជោគជ័យនៃកម្មវិធីអត្តសញ្ញាកម្មគ្រួសារក្រីក្រក្នុងរាជធានីភ្នំពេញ សម្រាប់ប្រើប្រាស់ជាទិន្នន័យគោលក្នុងការត្រួតពិនិត្យ ដើម្បីធានានូវយន្តការដែលបានបង្កើតឡើងតាមរយៈកម្មវិធីនេះ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។ វិធីសាស្ត្រចំរុះមួយ ដែលត្រូវបានប្រើប្រាស់មានការពិនិត្យមើលឯកសារដែលមានស្រាប់ របាយការណ៍ឃ្លាំមើលនានា ការសម្ភាសពាក់កណ្ដាលរៀបរយ និងការផ្ដល់អនុសាសន៍នានាដោយផ្អែកលើការរកឃើញ។ ការវាយតម្លៃនេះគឺផ្អែកទៅលើការសិក្សាស្រាវជ្រាវដែលបានធ្វើឡើងតាមរយៈរបាយការណ៍ស្ទង់មតិរបស់អង្គការសមាគមធាងត្នោតនៅក្នុងរាជធានីភ្នំពេញ ឆ្នាំ២០១៧ ដែលបានរកឃើញថា រាជធានីភ្នំពេញមានទីតាំងសហគមន៍ក្រីក្រនៅតាមទីប្រជុំជនចំនួនសរុប ២៧៧ទីតាំង និងរបាយការណ៍ផ្ទៃក្នុងដែលមិនបានផ្សព្វផ្សាយមួយទៀត ត្រូវបានផលិតឡើងក្នុងឆ្នាំ ២០១៩ ដែលបានសម្ភាសជាមួយនឹងតំណាងមកពីសហគមន៍ក្រីក្រនៅតាមទីប្រជុំជនចំនួន ២៣២ ទីតាំង អំពីប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩។

ការសិក្សាស្រាវជ្រាវអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានបំណងផ្ដល់នូវការយល់ដឹងមួយចំនួនទាក់ទងនឹង បទពិសោធន៍របស់សហគមន៍ក្រីក្រនៅតាមទីប្រជុំជននៅក្នុងរាជធានីភ្នំពេញ ដែលកំពុងស្វែងរក និងប្រើប្រាស់ប្រព័ន្ធនេះ។

### ២.២. លក្ខខណ្ឌជ្រើសរើស និងទំហំ

សហគមន៍ចំនួន ៣៧ ក្នុងចំណោមសហគមន៍ក្រីក្រនៅតាមទីប្រជុំជនចំនួន ២៧៧ ទីតាំង ត្រូវបានទាក់ទងដើម្បីចូលរួមក្នុងការស្រាវជ្រាវ ដែលរួមមាន ៥ ០១៩ គ្រួសារ ឬស្មើនឹង ៣ ៨៦០ ខ្នងផ្ទះ។ សហគមន៍នៅក្រៅរាជធានីភ្នំពេញមិនត្រូវបានរួមបញ្ចូលនៅក្នុងការស្រាវជ្រាវនេះទេ។

### ២.៣. ការប្រមូលព័ត៌មាន

ការប្រមូលព័ត៌មាន ត្រូវបានធ្វើឡើងនៅក្នុងខែឧសភា ឆ្នាំ២០២២ តាមរយៈការសម្ភាសជាមួយអ្នកតំណាងសហគមន៍ ដើម្បីទទួលបច្ចុប្បន្នភាពពីស្ថានភាព និងប្រភេទនៃប័ណ្ណសមធម៌របស់ពួកគេ។ កម្រងសំណួរមានបួនផ្នែក។ ផ្នែកទី១៖ សំណួរទូទៅស្ដីពីសហគមន៍ និងការប្រើប្រាស់ប័ណ្ណសមធម៌ រួមមានប្រភេទនៃសេវាកម្មនានា ដែលសហគមន៍ទទួលបាន និងការលំបាកដែលពួកគេបានជួបប្រទះអំឡុងពេលប្រើប្រាស់ប័ណ្ណ។ ស្ថានភាពសហគមន៍ដែលមិនមានប័ណ្ណក្រីក្រ ត្រូវបានសិក្សានៅក្នុងផ្នែកទី២។ ផ្នែកទី៣៖ ការស្ទង់មតិអំពីប្រសិទ្ធិភាពនៃដំណើរការចែកប័ណ្ណសមធម៌របស់អាជ្ញាធរ វិធីសាស្ត្រ និងពេលវេលាដែលអាជ្ញាធរផ្ដល់ព័ត៌មាន។ ផ្នែកទី៤៖ នីតិវិធីនៃការចែកប័ណ្ណសមធម៌ និងអនុសាសន៍នានារបស់សហគមន៍។

### ២.៤. ដែនកំណត់

ការសិក្សានេះ ត្រូវបានធ្វើឡើងជាមួយនឹងសហគមន៍គោលដៅចំនួន ៣៧ កន្លែង ហើយទិន្នន័យត្រូវបានប្រមូលតាមរយៈកម្រងសំណួរជាលាយលក្ខណ៍អក្សរ តាមរយៈការជួបសម្ភាសផ្ទាល់ និងតាមទូរស័ព្ទដូចទៅនឹងការសិក្សារបាយការណ៍ស្រាវជ្រាវកាលពីឆ្នាំ ២០១៩។ ដូចច្នេះ ការសិក្សានេះអាចជឿទុកចិត្តបានក្នុងកម្រិតដែលអ្នកផ្ដល់ចម្លើយបានស្ម័គ្រចិត្តផ្ដល់នូវក្នុងការស្រាវជ្រាវតែប៉ុណ្ណោះ។

ការសិក្សានេះមិនតំណាងឱ្យស្ថានភាពរបស់សហគមន៍ក្រីក្រទាំងអស់នៅក្នុងរាជធានីភ្នំពេញនោះទេ។ ដូច្នេះការសិក្សា

នេះគួរតែយកមកប្រើប្រាស់ ដើម្បីបង្ហាញពីនិន្នាការសំខាន់ៗ ហើយក្រុមអ្នកស្រាវជ្រាវទទួលស្គាល់ថាសហគមន៍មួយចំនួន ដែលមិនបានចូលរួមក្នុងការស្រាវជ្រាវនេះ អាចនឹងមិនយល់ស្របនឹងការរកឃើញ។

ការសិក្សាស្រាវជ្រាវបន្តត្រូវបានធ្វើឡើង ក្រោយពេលនៃការដាក់ឱ្យដំណើរការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំ ដែលបានចាប់ផ្តើមអំឡុងពេលនៃការសិក្សាស្រាវជ្រាវក្នុងឆ្នាំ ២០១៩ និង២០២០។

របាយការណ៍នេះ សម្រាប់ផ្តល់ជាទិន្នន័យគោលប៉ុណ្ណោះ។ អង្គការសមាគមធាងត្នោត កំពុងធ្វើការងារជាមួយដៃគូរ កម្មវិធីមួយចំនួន ដែលទទួលខុសត្រូវលើការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីធានាថាកម្មវិធីនេះ អាចទទួលបានគ្រប់ពលរដ្ឋដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះ។

# ៣. ការរកឃើញសំខាន់ៗ

**ផ្នែកទី១៖ ព័ត៌មានទូទៅអំពីការទទួលបានប័ណ្ណសមធម៌**

**ចំនួនប្រជាពលរដ្ឋទទួលបានប័ណ្ណសមធម៌ពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការ**

គួរឱ្យចាប់អារម្មណ៍ផងដែរ អង្គការសមាគមធាងត្នោតបានរកឃើញថា ក្នុងចំណោមសហគមន៍ចំនួន ៣៧ ដែលត្រូវបានពិនិត្យតាមដាននៅក្នុងឆ្នាំ ២០២២ មានតែសហគមន៍ចំនួន ៣ ប៉ុណ្ណោះ ដែលពុំទាន់ទទួលបានប័ណ្ណសមធម៌ ដែលមានចំនួន ២៤២ ខ្នងផ្ទះ និង២៤៣ គ្រួសារ។ ភាគច្រើនសមាជិកនៅក្នុងសហគមន៍គោលដៅទាំងនេះប្រកបរបរជាកម្មកររោងចក្រ កម្មករកាត់ដេរ និងការងារដែលទទួលបានប្រាក់កម្រៃទាបផ្សេងទៀត។ តំណាងសហគមន៍បានឆ្លើយប្រាប់ថាស្ថានភាពហិរញ្ញវត្ថុក្នុងគ្រួសាររបស់ប្រជាពលរដ្ឋទាំងនោះបានធ្លាក់ចុះកាន់តែខ្លាំងអំឡុងពេលរលកទីមួយ និងរលកទី២នៃការជំងឺរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ហើយពួកគេត្រូវរស់នៅក្នុងសភាពលំបាកខ្លាំង។ ជាពិសេសនោះ មានគ្រួសារមួយមានសមាជិកដែលមានពិការភាព។ គ្រួសារជាច្រើនដែលមិនមានប័ណ្ណសមធម៌បានសម្តែងការព្រួយបារម្ភអំពីស្ថានភាពគ្រួសាររបស់ពួកគេដល់អាជ្ញាធរ ក៏ប៉ុន្តែពុំទាន់ទទួលបានការឆ្លើយតប និងដំណោះស្រាយនៅឡើយទេ។ ប្រជាសហគមន៍ម្នាក់ព្រួយបារម្ភថាស្ថានភាពអសន្តិសុខនៃការកាន់កាប់ដីធ្លីរបស់ពួកគេគឺជាមូលហេតុដែលធ្វើឱ្យពួកគេមិនទទួលបានប័ណ្ណសមធម៌។




*សម្ដីរបស់សហគមន៍៖ ឥឡូវនេះ ខ្ញុំកំពុងទន្ទឹងរង់ចាំជំនួយគាំទ្រពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់គ្រួសាររបស់ខ្ញុំដែលស្ថិតក្នុងស្ថានភាពលំបាកនេះ។*

ក្រាហ្វិចទី ១៖ ចំនួនសហគមន៍គោលដៅដែលមានប័ណ្ណសមធម៌ក្នុងឆ្នាំ ២០២២

ប្រជាសហគមន៍មានប័ណ្ណសមធម៌ដែលត្រូវបានសម្ភាសភាគច្រើន បាននិយាយថាពួកគេពុំមានឯកសារអត្រានុកូលដ្ឋានសំខាន់ៗផ្សេងទៀត ដូចជាសៀវភៅគ្រួសារឡើយ។ នេះបង្ហាញឱ្យឃើញថាប្រជាសហគមន៍ក្រីក្រអាចទទួលបានប័ណ្ណសមធម៌ និងសេវារបស់ប័ណ្ណនេះបានដោយមិនចាំបាច់មានឯកសារជាក់លាក់ណាមួយឡើយ។ យ៉ាងណាមិញ ការកង្វះឯកសារសម្គាល់អត្តសញ្ញាណនៅតែជាបញ្ហាដែលកំពុងប្រឈមដល់ប្រជាពលរដ្ឋក្រីក្រនៅក្នុងទីក្រុង និងតាមជនបទ ជាពិសេសទាក់ទងនឹងបញ្ហាអសុវត្ថិភាពនៃការកាន់កាប់ដីធ្លី។

បើយោងតាមការរកឃើញនៃការស្រាវជ្រាវ នៅក្នុងសហគមន៍គោលដៅចំនួន ៣៤ យ៉ាងហោចណាស់មួយគ្រួសារមានប័ណ្ណសមធម៌ និងទទួលបានជំនួយគាំទ្រទាន់ពេលវេលា ក្នុងអំឡុងពេលរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩។ ថ្វីត្បិតតែយ៉ាងនេះក្ដី នៅក្នុងសហគមន៍ទាំងនេះមានតែក្រុមគ្រួសារមួយចំនួនតូចប៉ុណ្ណោះ ដែលមានប័ណ្ណសមធម៌ ដូចបានបង្ហាញក្នុងតារាងទី ១។

ក្នុងចំណោមគ្រួសារចំនួន ៤ ៧៧៦ ដែលរស់នៅក្នុងសហគមន៍ទាំង ៣៤ នេះ មានតែគ្រួសារចំនួន ១ ០៦៩ (ស្មើ ២២%ភាគរយ) ប៉ុណ្ណោះដែលទទួលបានប័ណ្ណសមធម៌មុនពេលបញ្ចប់រលកទីពីរនៃការរីករាលដាលនៃឆ្លងជំងឺកូវីដ-១៩ ក្នុងឆ្នាំ ២០២២។

ការបែងចែកលម្អិតនៃចំនួនគ្រួសារដែលមានប័ណ្ណសមធម៌ បង្ហាញឱ្យឃើញថាភាគច្រើននៃសហគមន៍ទាំង ៣៤នេះ មានចំនួនគ្រួសារតិចជាង ៥០ ដែលមានប័ណ្ណសមធម៌ (តារាងទី ១)។ ៥០គ្រួសារប៉ុណ្ណោះកំពុងកាន់ប័ណ្ណនេះ (តារាង១)។

តារាងទី១៖ ការប្រៀបធៀបរវាងចំនួនគ្រួសារសរុបក្នុងសហគមន៍នីមួយៗ និងចំនួនគ្រួសារដែលទទួលបានប័ណ្ណសមធម៌ពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គិតត្រឹមឆ្នាំ ២០២២។ គួរចំណាំថាឈ្មោះសហគមន៍ត្រូវបានដកចេញក្នុងគោលបំណងរក្សានូវសុវត្ថិភាព។

| ក្រោម ២០ គ្រួសារមាន ប័ណ្ណសមធម៌ក្នុងសហគមន៍នីមួយៗ | | ពី ២១ ទៅ ៥០ គ្រួសារ មានប័ណ្ណសមធម៌ | | លើសពី ៥០ គ្រួសារ មានប័ណ្ណសមធម៌ | |
|---|---|---|---|---|---|
| ចំនួនគ្រួសារសរុបនៅក្នុងសហគមន៍ | ចំនួនគ្រួសារដែលមានប័ណ្ណសមធម៌ | ចំនួនគ្រួសារសរុបនៅក្នុងសហគមន៍ | ចំនួនគ្រួសារដែលមានប័ណ្ណសមធម៌ | ចំនួនគ្រួសារសរុបនៅក្នុងសហគមន៍ | ចំនួនគ្រួសារដែលមានប័ណ្ណសមធម៌ |
| ១៤០ | ៥ | ៨០ | ៤០ | ១៣៨ | ៧០ |
| ១១០ | ៣ | ១២១ | ២៥ | ៣៦៧ | ១០៥ |
| ៨៣ | ១ | ២៤ | ២២ | ១១៣ | ៧៥ |
| ៧៥ | ៣ | ១៤៥ | ២៥ | ៣៩២ | ២៤៤ |
| ៩៣ | ៨ | ២៤៤ | ៥០ | ៦៣ | ៦៣ |
| ៣០ | ១០ | ១១២ | ២៥ | | |
| ១៣០ | ១ | ១៤០ | ៥០ | | |
| ៤២ | ១៥ | ៧៦៦ | ២៤ | | |
| ២៥០ | ១២ | ៤៦ | ២០ | | |
| ៣៣ | ៦ | ១៦០ | ២៤ | | |
| ៨០ | ៧ | ១០៤ | ៤៤ | | |
| ៥០ | ៦ | ២៥០ | ៤៤ | | |
| ៧២ | ៦ | | | | |
| ២៧ | ១៩ | | | | |
| ១៥០ | ៧ | | | | |
| ៤២ | ៤ | | | | |
| ១០៤ | ៦ | | | | |

**បណ្តឹងតវ៉ាអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់សហគមន៍ក្រីក្រនៅក្នុងទីក្រុង**

៧៣ ភាគរយ នៃចំនួន ៣៧សហគមន៍បានផ្តល់បទសម្ភាសទាក់ទងនឹងការតវ៉ាជំទាស់នឹងដំណើរការកម្មវិធីនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងរបៀបនៃការអនុវត្តរបស់អាជ្ញាធរ។ ការតវ៉ាភាគច្រើនគឺពាក់ព័ន្ធនឹងដំណើរការស្នើសុំប័ណ្ណសមធម៌មានសេវាមិនសូវល្អ ដំណើរការសម្ភាសមានភាពយឺតយ៉ាវ និងការឆ្លើយតបទៅនឹងសំណើរបស់សហគមន៍មានភាពយឺតយ៉ាវ។ សហគមន៍ខ្លះ ក៏បានលើកឡើងថែមទៀតនូវក្តីបារម្ភអំពីភាពលម្អៀង ដោយមើលឃើញថាប្រជាសហគមន៍ដែលទទួលបានប័ណ្ណសមធម៌ មានភាពជិតដិតជាមួយនឹងអាជ្ញាធរ។ ហេតុនេះហើយដែលបង្កឱ្យមានការប្តឹងតវ៉ាទាមទារនូវតម្លាភាព និងការតាមដានអោយកាន់តែមានច្រើននៅក្នុងដំណើរការអនុវត្ត ជាពិសេសដោយសារអាជ្ញាធរងាយនឹងផ្តល់អាទិភាពឱ្យទៅអ្នកដែលពួកគេស្គាល់។

*សម្តីរបស់សហគមន៍៖ ប័ណ្ណសមធម៌ត្រូវបានចែកឱ្យតែអ្នកមាន មិត្តភក្តិ ឬសាច់ញាតិរបស់ពួកគេ។ ពេលខ្លះ ខ្ញុំមានអារម្មណ៍ថាខកចិត្តចំពោះដំណើរការនេះ ហើយខ្ញុំតែងតែឆ្ងល់ថាហេតុអ្វីបានជាប័ណ្ណសមធម៌នេះគេចែកឱ្យតែអ្នកមាន មិនចែកឱ្យអ្នកក្រពិតប្រាកដ។*

ស្ទើរតែ ៣២ ភាគរយ នៃចំនួនគ្រួសារទាំងអស់ដែលទទួលបានប័ណ្ណសមធម៌ត្រូវបានចាត់បញ្ចូលជាគ្រួសារក្រីក្រប្រភេទក្រ ១ (ក្រ១ មានន័យថាក្រីក្រខ្លាំងយោងតាមប្រព័ន្ធវាយតម្លៃដាក់ពិន្ទុរបស់ក្រសួងផែនការ)។ ពួកគេត្រូវការកម្មវិធីនេះជាខ្លាំងដើម្បីបង់ថ្លៃសេវាមន្ទីរពេទ្យ និងធ្វើឱ្យស្ថានភាពរស់នៅរបស់ពួកគេមានភាពប្រសើរឡើង។

សហគមន៍ក្រីក្ររស់នៅក្នុងទីក្រុងចំនួន ៣៤ ទីតាំង ដែលមានប័ណ្ណសមធម៌បានស្នើសុំការគាំទ្រជំនួយហិរញ្ញវត្ថុសាច់ប្រាក់ស្បៀងអាហារប្រចាំថ្ងៃ និងសេវាសាធារណៈ ដូចជាសេវាអប់រំ សេវាថែទាំព្យាបាល និងជំនួយជាសាច់ប្រាក់។ ទោះបីជាយ៉ាងនេះក្តី មានករណីជាច្រើនដែលអ្នកផ្តល់សេវាមិនបានផ្តល់អាទិភាព និងជំនួយដល់អ្នកដែលមានប័ណ្ណសមធម៌ឡើយ។ ឧទាហរណ៍ សមាជិកសហគមន៍ម្នាក់ បានអះអាងថាវេជ្ជបណ្ឌិតនៅពេទ្យរដ្ឋ ជាទូទៅមិនដឹងច្បាស់អំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឬមិនស្ម័គ្រចិត្តជួយដល់អ្នកមានប័ណ្ណសមធម៌ឡើយ។

*សម្តីរបស់សហគមន៍៖ មន្ត្រីរាជរដ្ឋាភិបាលដែលធ្វើការនៅពេទ្យរដ្ឋមិនបានរវីរវល់ឆ្លើយនឹងតបខ្ញុំទេ។ ពួកគាត់គ្រាន់តែដាក់សារ៉ូមឱ្យខ្ញុំ ហើយទុកខ្ញុំចោលមិនមកមើលខ្ញុំទេ។ ពួកគាត់ដូចជាមិនសូវខ្វល់ពីអ្នកក្រសោះ។*

**ផ្នែកទី ២៖ ព័ត៌មានទូទៅអំពីសហគមន៍ដែលមិនមានប័ណ្ណសមធម៌**

អ្នកឆ្លើយតប មកពីសហគមន៍ចំនួន ៣ ដែលមិនមានប័ណ្ណសមធម៌នោះ បានអះអាងថាពួកគេបានឮអំពីប័ណ្ណសមធម៌តាមរយៈសហគមន៍ជិតខាងរបស់ពួកគេ និងទទួលវគ្គបណ្តុះបណ្តាលពីអង្គការមិនមែនរាជរដ្ឋាភិបាល។ ប៉ុន្តែ ព័ត៌មានទាំងអស់នេះហាក់ដូចជានៅមិនទាន់គ្រប់គ្រាន់នៅឡើយ ព្រោះពួកគេនៅតែមិនទាន់ទទួលបានប័ណ្ណសមធម៌។ អង្គការមិនមែនរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតអាចជាផ្នែកចម្បងក្នុងការលើកកម្ពស់ការយល់ដឹងអំពីប្រព័ន្ធ និងនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

*សម្តីរបស់សហគមន៍៖ ខ្ញុំមិនដឹងថាហេតុអ្វីបានជាអាជ្ញាធរមិនមកប្រាប់ពួកយើងអំពីប័ណ្ណសមធម៌នេះទេ បើទោះបីជាពួកយើងកំពុងរស់នៅជាមួយនឹងទឹកជន់លិច និងភាពក្រីក្រក្តី។*

**ផ្នែកទី ៣៖ ដំណើរការនៃការចែកប័ណ្ណសមធម៌របស់អាជ្ញាធរមូលដ្ឋាន**

៥១,៤%ភាគរយ នៃចំនួនសហគមន៍ទាំង ៣៧ ដែលផ្តល់បទសម្ភាស បានអះអាងថាបានទទួលព័ត៌មានអំពីអត្ថប្រយោជន៍នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ អាជ្ញាធរមូលដ្ឋានបានផ្តល់ព័ត៌មានទៅដល់សហគមន៍តាមរយៈមធ្យោបាយជាច្រើនផ្សេងៗ ដូចជាការផ្សព្វផ្សាយតាមមេក្រូបំពងសំឡេង ការប្រាប់ផ្ទាល់មាត់នៅតាមផ្ទះ ឬខិតប័ណ្ណព័ត៌មាន។ វិធីសាស្ត្រទាំងនេះនៅមិនទាន់គ្រប់គ្រាន់ ដើម្បីលើកកម្ពស់ការយល់ដឹងទៅដល់គ្រប់សហគមន៍ទាំងអស់នោះឡើយ ជាពិសេសក៏មានប្រជាសហគមន៍ខ្លះមិនបាននៅផ្ទះ ខណៈពេលដែលអាជ្ញាធរចុះទៅជួប។ ពលរដ្ឋនៅក្នុងសហគមន៍ចំនួន ៤ ដែលស្មើនឹង (ដែលមាន ៧៤៤ គ្រួសារ) ក៏បានប្រាប់ថា អាជ្ញាធររបស់ពួកគេបានទុកខិតប័ណ្ណព័ត៌មាននៅមុខផ្ទះ នៅខណៈពេលដែលពួកគេមិនបាននៅផ្ទះ ហើយពួកគេ

ដឹងអំពីប័ណ្ណសមធម៌នេះ។ ប្រជាសហគមន៍នៅតែពឹងផ្អែកខ្លាំងទៅលើអាជ្ញាធរក្នុងការផ្តល់ដំណឹងដល់ពួកគេ។ ការយល់ដឹងផ្សព្វផ្សាយព័ត៌មានគួរតែមានលក្ខណៈទូលំទូលាយជាងនេះ ខណៈដែលព័ត៌មាន មានទាំងនៅតាមលើប្រព័ន្ធអនឡាញ និងនៅក្រុមការងារថ្នាក់មូលដ្ឋាន ជាងនេះទៅទៀត ប្រជាសហគមន៍អាចសួរព័ត៌មាន និងស្នើសុំទៅរកក្រុមការងារថ្នាក់ភូមិ ដើម្បីបានយល់ដឹងអំពីប័ណ្ណសមធម៌ និងការស្នើសុំរៀបចំសម្ភាសផ្ទាល់តែម្តង។




ក្រាហ្វិចទី២៖ ដំណើរការនៃការចែកប័ណ្ណសមធម៌របស់អាជ្ញាធរមូលដ្ឋាន

**ផ្នែកទី ៤៖ នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**

៦០ភាគរយ នៃប្រជាសហគមន៍ដែលបានផ្តល់បទសម្ភាស បានអះអាងថាអាជ្ញាធរមូលដ្ឋានបានសម្ភាសតាមគ្រួសារ ហើយ ១៨ ភាគរយ ឆ្លើយថាអាជ្ញាធរគ្រាន់តែចុះជួបពួកគេ ដើម្បីតាមដានស្ថានភាពទូទៅរបស់សហគមន៍តែប៉ុណ្ណោះ។ ៧ ភាគរយនៃអ្នកផ្តល់បទសម្ភាសបាននិយាយថាអាជ្ញាធរគ្រាន់តែផ្តល់ដំណឹងអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលគេគ្រោងនឹងអនុវត្តក្នុងពេលឆាប់ៗតែប៉ុណ្ណោះ។ ៤ ភាគរយ បានប្រាប់ថាអាជ្ញាធរគ្រាន់តែមកថតយករូបប្រជាសហគមន៍ ដោយមិនបានប្រាប់ឱ្យច្បាស់អំពីគោលបំណងឡើយ។ ១១ភាគរយ នៃតំណាងសហគមន៍នៅតែមិនទាន់បានដឹងអំពីកម្មវិធីនេះនៅឡើយ។




ក្រាហ្វិចទី៣៖ នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ប្រហែល ៥២ ភាគរយ នៃអ្នកឆ្លើយតបសម្ភាសគិតថាកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះនៅមានភាពលម្អៀងខ្លាំង ហើយការស្នើសុំចុះឈ្មោះ និងការទទួលបានអត្ថប្រយោជន៍ពីកម្មវិធីនេះមានលក្ខណៈពិបាក។ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធនៅពុំទាន់បានប្រាប់ឱ្យប្រជាពលរដ្ឋបានយល់ច្បាស់អំពីកម្មវិធី និងនីតិវិធីរបស់កម្មវិធីនេះនៅឡើយ។




ក្រាហ្វិចទី៤៖ ភាពលម្អៀងនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ជិត ៧០ ភាគរយ នៃសហគមន៍ទាំង ៣៧ បានស្នើឱ្យក្រសួងផែនការកែលម្អផ្នែកខ្លះនៃនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ស្របពេលជាមួយគ្នានេះផងដែរ គួរមាននីតិវិធីតាមដានលើដំណើរការកម្មវិធីនេះ ដើម្បីធានានូវប្រសិទ្ធភាព និងភាពត្រឹមត្រូវសម្រាប់ប្រជាពលរដ្ឋក្រីក្រ។ ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ មានយន្តការសម្រាប់ផ្តល់ការណែនាំ និងការតវ៉ា ដែលសង្ឃឹមថានឹងមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាភាពលម្អៀង និងការរើសអើងនាថ្ងៃអនាគតបាន។




ក្រាហ្វិចទី៥៖ ការស្នើសុំឱ្យមានការកែលម្អផ្នែកខ្លះនៃនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

# ៤. សេចក្តីសន្និដ្ឋាន

ប្រជាពលរដ្ឋចំនួន ២៤៣ គ្រួសារ ដែលគ្រប់លក្ខខណ្ឌទទួលបានអត្ថប្រយោជន៍ពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅពុំទាន់មានប័ណ្ណសមធម៌នៅឡើយទេ នៅក្នុងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋចំនួន ២៤៣ គ្រួសារ ដែលមកពីសហគមន៍ចំនួន ៣ ក្នុងចំណោមសហគមន៍ចំនួន ៣៧ ទីតាំងដែលបានសម្ភាស បានអះអាងថាពួកគេមិនទទួលបានព័ត៌មានអំពីប្រព័ន្ធនេះទេ។ ដូចនេះសមាជិកសហគមន៍ទាំងនោះ ពុំទាន់ទទួលបានប័ណ្ណ និងសេវាចាំបាច់នៅឡើយ។ លទ្ធផលសំខាន់នៃការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថាការយល់ដឹងអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវតែពង្រឹងបន្ថែម ដើម្បីឱ្យប្រព័ន្ធនេះ អាចបម្រើដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះទាំងអស់នៅក្នុងរាជធានីភ្នំពេញ។

សហគមន៍នៅមិនទាន់មានការយល់ដឹងច្បាស់លាស់ទាក់ទងនឹងការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរ និងការប្រើប្រាស់ប្រព័ន្ធ។ កិច្ចសហប្រតិបត្តិការ និងជំនួយពីស្ថាប័ននៅមានកង្វះខាត ដូចជាអង្គការមិនមែនរាជរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល។ អង្គការមិនមែនរាជរដ្ឋាភិបាលអាច ឬដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាសហគមន៍អំពីប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ នៅថ្ងៃខាងមុខ ជាពិសេសនៅពេលដែលប្រព័ន្ធនេះត្រូវបានបំប្លែងទៅឌីជីថលទាំងស្រុង។

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលជាជំហានមួយដែលឈានទៅរកបរិយាប័ន្នសង្គម ការទទួលបានយុត្តិធម៌ ការថែទាំសុខភាព ការអប់រំ គួរត្រូវបានអនុវត្តឱ្យល្អប្រសើរឡើងនៅក្នុងតំបន់ទីក្រុង។ ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ អាចផ្តល់ភាពងាយស្រួលកាន់តែច្រើនដល់សហគមន៍ ប៉ុន្តែចាំបាច់ត្រូវមានការពិនិត្យតាមដាន ដើម្បីធានានូវតម្លាភាព និងគណនេយ្យភាពមាននៅក្នុងការអនុវត្តប្រព័ន្ធនេះផងដែរ។

# ៥. អនុសាសន៍

**ដៃគូបច្ចេកទេស និងម្ចាស់ជំនួយ**

- បង្កើតយន្តការពិនិត្យលើការអនុវត្តកម្មវិធីរបស់អាជ្ញាធរ ដើម្បីធានានូវភាពមិនលម្អៀង និងការមិនរើសអើង។
- ផ្តល់ធនធាន ថវិកា វគ្គបណ្តុះបណ្តាល និងតម្រូវការផ្សេងទៀតបន្ថែមដល់អាជ្ញាធរមូលដ្ឋានដើម្បីឱ្យពួកគេមានសមត្ថភាពអាចអនុវត្តកម្មវិធីបានល្អប្រសើរ។
- បង្កើនការគាំទ្រដល់អង្គការសង្គមស៊ីវិលដែលធ្វើការងារលើការកាត់បន្ថយភាពក្រីក្រ និងបញ្ហាសិទ្ធិមនុស្ស ដើម្បីឱ្យពួកគេអាចចូលរួមក្នុងការឃ្លាំមើលការអនុវត្តកម្មវិធីនេះ។

**ក្រសួងផែនការ**

- ដឹកនាំ ឬផ្តល់សិទ្ធិធ្វើការស៊ើបអង្កេត ដើម្បីធានាថាអាជ្ញាធរមិនប្រើប្រាស់អារម្មណ៍ផ្ទាល់ខ្លួនធ្វើឱ្យមានភាពលម្អៀង មិនប្រកាន់និន្នាការនយោបាយ ឬមិនរើសអើងក្នុងទម្រង់ណាមួយឡើយ។
- តាមដាន និងណែនាំដល់អាជ្ញាធរមូលដ្ឋានដែលបានអនុវត្តខុសពីដំណើរការក្នុងការផ្តល់ប័ណ្ណសមធម៌ ដូចជាការអនុវត្តយឺតយ៉ាវ និងកង្វះព័ត៌មាន ជាដើម។
- ផ្សព្វផ្សាយព័ត៌មាន និងធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះតាមរយៈមធ្យោបាយនានាឱ្យបានច្រើនតាមដែលអាចធ្វើបាន។
- កែសម្រួលកម្រងសំណួរអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងទីក្រុង ដើម្បីធានាភាពត្រឹមត្រូវសម្រាប់គ្រួសារដែលមានស្ថានភាពក្រីក្រពិតប្រាកដ។

**អាជ្ញាធរមូលដ្ឋាន**

- ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានដល់សាធារណជនតាមរយៈមធ្យោបាយផ្សេងៗអំពីយន្តការគាំពារសង្គមដើម្បីឱ្យពួកគេទទួលបានអត្ថប្រយោជន៍ពីយន្តការទាំងនោះ។
- ផ្តល់ដំណឹងដល់សមាជិកសហគមន៍ឱ្យបានគ្រប់គ្រាន់ទាក់ទងនឹងកាលបរិច្ឆេទ និងពេលវេលាសម្ភាស
- សហការឱ្យកាន់តែច្រើនជាមួយអង្គការមិនមែនរាជរដ្ឋាភិបាលនៅមូលដ្ឋានដើម្បីធានាថាគ្រប់ប្រជាសហគមន៍ក្រីក្រទាំងអស់ទទួលបានប័ណ្ណសមធម៌នេះ។

**អង្គការសង្គមស៊ីវិល**

- រិះរកវិធីផ្សេងៗក្នុងការចែកចាយ និងផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ស្របតាមស្ថានភាពក្នុងតំបន់នីមួយៗ។
- ធ្វើការជាមួយអាជ្ញាធរឃុំ ឬសង្កាត់ដើម្បីទទួលបាន និងផ្តល់ព័ត៌មានអំពីគ្រួសារក្រីក្រនៅក្នុងទីក្រុង និងស្ថានភាពសហគមន៍
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតដើម្បីបញ្ចៀសនូវការផ្តល់ព័ត៌មានដដែលមកពីប្រភពផ្សេងគ្នាដល់សហគមន៍ (ឧទាហរណ៍៖ គួរមានប្រព័ន្ធតាមដានមើល ឬគំនូសផែនទីមួយដែលអង្គការមិនមែនរដ្ឋាភិបាលអាចមើលដឹងថា អង្គការណាខ្លះដែលកំពុងធ្វើការសកម្មនៅក្នុងតំបន់ និងសហគមន៍ផ្សេងៗពីគ្នា)។

**សមាជិកសហគមន៍**

- ស្វែងរកក្រុមការងារភូមិ ឬប្រធានភូមិ និងអាជ្ញាធរដទៃផ្សេងទៀតដើម្បីទទួលបានព័ត៌មានទាក់ទងនឹងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
- ប្រើប្រាស់ឧបករណ៍ និងព័ត៌មានតាមប្រព័ន្ធអនឡាញដើម្បីទទួលបានព័ត៌មានថ្មីៗអំពីដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
- សមាជិកសហគមន៍គួរតែសកម្មក្នុងការចុះឈ្មោះក្នុងប្រព័ន្ធ ពិសេសប្រព័ន្ធអត្តសញ្ញាណកម្មតាមការស្នើសុំដែលមានលក្ខណៈងាយស្វែងរកបានតាមទូរស័ព្ទស្មាតហ្វូន។

អង្គការសហគមធាងត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO

ទូរសព្ទទំនាក់ទំនង៖ ០២៣ ៥៥៥ ១៩៦៤
គេហទំព័រ៖ http://teangtnaut.org
ហ្វេសប៊ុក៖ https://www.facebook.com/sttcambodia